# វេទិការៀនសូត្រស្ដីពីការគ្រប់គ្រងធនធានមនុស្សលើកទី ៤៧

ក្រោមប្រធានបទ **លក្ខខណ្ឌចម្បងនៃច្បាប់ការងារសម្រាប់អ្នកអនុវត្តផ្នែកធនធានមនុស្ស**

*ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០២៣*

*ម៉ោង ៨:០០ ដល់ ៥:០០ ល្ងាច*

*តាមរយៈការចូលរួមផ្ទាល់*

**ទីតាំងមជ្ឈមណ្ឌលជាយកូនៀ**

## ១. សេចក្ដីផ្ដើម

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) ជាអង្គការសមាជិកភាពដ៏ធំ និងមានវ័យចំណាស់ជាងគេមួយនៅក្នុងប្រទេសកម្ពុជា។ រហូតមកដល់ខែមីនា ឆ្នាំ២០២៣ អង្គការ គ.ស.ក មានសមាជិកជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសចំនួន ១៩១។ បច្ចុប្បន្ននេះ អង្គការ គ.ស.ក បានកំពុងអនុវត្តកម្មវិធីមជ្ឈមណ្ឌលអភិបាលកិច្ចដំណាក់កាលទី៤ ពីឆ្នាំ២០២១ ដល់ ២០២៣។ កម្មវិធីនេះ មានគោលបំណងសំខាន់ចំនួនពីរៈ ទី១ គឺធ្វើឱ្យប្រសើរឡើងនូវបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិល និងទី២ មជ្ឈមណ្ឌលធនធានប្រកបដោយនិរន្តរភាព សម្រាប់អង្គការសង្គមស៊ីវិលទាំងនៅថ្នាក់ជាតិ និងក្រោមជាតិ។

នាថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ កន្លងមកនេះ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានចេញប្រកាសអន្តរក្រសួង (ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ដើម្បីកំណត់ថ្ងៃនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់ បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្ដីពីការងារ។ ផ្អែកលើគេហទំព័រ (https://mlvt.gov.kh) របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងមានសេវាកម្មសំខាន់ៗជាច្រើន ហើយដែលក្នុងសេវាកម្មសំខាន់ៗទាំងអស់នោះមានសេវាកម្មចំនួនពីរ (សេវាពាក់ព័ន្ធវិស័យការងារ និងសេវាពាក់ព័ន្ធជនបរទេស) ដែលអង្គការសង្គមស៊ីវិលកំពុងចង់ដឹង និងស្វែងយល់បន្ថែមក្នុងគោលបំណងប្រើប្រាស់សេវាកម្មទាំងពីរនេះ ប្រកបដោយប្រសិទ្ធិភាព ពិសេសមានលទ្ធភាពគ្រប់គ្រាន់អាចអនុលោមតាមបទបញ្ញត្តិនៃច្បាប់ស្ដីពីការងារ។

កន្លងមក អង្គការសង្គមស៊ីវិល ក៏មានបញ្ហាប្រឈមផងដែរ ទាក់ទងទៅនឹងការធ្វើកិច្ចសន្យាបុគ្គលិកជាក់ស្ដែងនៅក្នុងវេទិការៀនសូត្រស្ដីពីការគ្រប់គ្រងធនធានមនុស្សថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០២២ មានសំនួរជាច្រើនទៅកាន់មន្ត្រីជំនាញមកពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ស្ដីពីការធ្វើកិច្ចសន្យាបុគ្គលិកដើម្បីឲ្យស្របទៅនឹងច្បាប់ស្ដីពីការងារ។

ដូច្នេះ ដើម្បីឱ្យអង្គការសង្គមស៊ីវិលអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការអនុលោមតាមសេចក្ដីប្រកាសស្ដីពីរបបសន្តិសុខសង្គម ការប្រើប្រាស់សេវាកម្មក្រសួងការងារប្រកបដោយប្រសិទ្ធិភាព និងការធ្វើកិច្ចសន្យាបុគ្គលិកបានត្រឹមត្រូវស្របទៅតាមច្បាប់ស្ដីពីការងារ អង្គការ គ.ស.ក នឹងរៀបចំវេទិការៀនសូត្រស្ដីពី ***លក្ខខណ្ឌចម្បងនៃច្បាប់ការងារសម្រាប់អ្នកអនុវត្តផ្នែកធនធានមនុស្ស*** ដែលវេទិកានេះ នឹងប្រព្រឹត្តឡើងនា

ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ នៅមជ្ឈមណ្ឌលដាយកូនៀ អាសយដ្ឋានផ្ទះលេខ ១៩ ផ្លូវ៣៣០ សង្កាត់បឹងកេងកង៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

## ២. គោលបំណងនៃវេទិការៀនសូត្រ

ក្នុងរយៈពេលមួយថ្ងៃពេញនាថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ អង្គការសង្គមស៊ីវិលនឹងបាន៖

1. បង្កើនការយល់ដឹង និងអនុលោមភាពតាមសេចក្តីប្រកាសអន្តរក្រសួងខាងលើ
2. រៀនសូត្រពីរបៀបប្រើប្រាស់ និងអនុលោមតាមប្រព័ន្ធស្វ័យប្រវត្តិកម្មការងារ
3. ស្វែងយល់អនុលោមភាពច្បាប់ការងារសម្រាប់អង្គការសង្គមស៊ីវិល
4. ពង្រីកទំនាក់ទំនងក្នុងចំណោមអ្នកកាន់តួនាទីផ្នែកគ្រប់គ្រងធនធានមនុស្ស។

## ៣. អ្នកចូលរួម និងការកំណត់តម្លៃនៃការចូលរួមក្នុងវេទិកាវៀនសូត្រ

វេទិកានេះ ត្រូវបានរៀបចំឡើងសម្រាប់ អ្នកជំនាញវិជ្ជាជីវៈ និងអ្នកប្រតិបត្តិការគ្រប់គ្រងធនធានមនុស្ស ដែលអញ្ជើញមកពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា។

- **ការចូលរួមដោយផ្ទាល់**
  - **ផ្តល់ជូនសម្រាប់តែអង្គការសមាជិក របស់ អង្គការ គ.ស.ក តែប៉ុណ្ណោះ**
  - **ផ្តល់ជូន ០២ កន្លែង សម្រាប់អង្គការសមាជិកនីមួយៗ**
  - **បើមានអង្គការសមាជិករបស់ អង្គការ គ.ស.ក មកលើស (ចាប់ពីអ្នកទី៣ទៅគឺ២៥USD/ម្នាក់)**
  - **ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលមិនមែនជាសមាជិកអង្គការ គ.ស.ក ចង់ចូលរួមដោយផ្ទាល់ត្រូវបង់ថ្លៃ ៥០ដុល្លារក្នុងម្នាក់/វគ្គ (ប្រសិនជានៅមានកន្លែង)។**

**សម្គាល់៖** ចំនួនមានកំណត់ សូមចុះឈ្មោះជាមុនតាមរយៈតំណរចុះឈ្មោះដែលបានផ្តល់ជូន។
សូមធ្វើការចុចលើតំណភ្ជាប់ខាងក្រោមដើម្បីចុះឈ្មោះចូលរួម៖
https://www.ccc-cambodia.org/en/resources/event-calendar/2023-05-18/hr-learning-forum-7

## ៤. របៀបវារៈ

| ម៉ោង | មាតិកា | អ្នកសម្របសម្រួល |
|---|---|---|
| ០៧:៤០ -០៨:១៥ | ការចុះឈ្មោះអ្នកចូលរួម | ក្រុមការងារ គ.ស.ក |
| ០៨:១៥-០៨:៣០ | - ការណែនាំពី បទបញ្ជាផ្ទៃក្នុងសម្រាប់វេទិការៀនសូត្រ<br>- គោរពភ្លេងជាតិ<br>- ប្រកាសគោលបំណងវេទិការៀនសូត្រ | **អ្នករៀបចំកម្មវិធី**<br>អង្គការ គ.ស.ក |

| | | |
|---|---|---|
| ០៨:៣០-៨:៤០ | កិច្ចស្វាគមន៍ដោយតំណាងអង្គការ គ.ស.ក<br><br>មតិបើកកម្មវិធីដោយតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | តំណាងអង្គការ គ.ស.ក<br><br>តំណាងក្រសួងការងារ |
| ៨:៤០ -៨:៤៥ | ការថតរូបជុំគ្នា | |
| ៨:៤៥ -១០:១៥ | **<u>បទបង្ហាញស្តីពីៈ របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។</u>**<br>• លក្ខខណ្ឌ និងតាវកាលិក សោធនជរាភាព<br>• លក្ខខណ្ឌ និងតាវកាលិក វិភាជន៍ជរាភាព<br>• លក្ខខណ្ឌ និងតាវកាលិក សោធនទុព្វលភាព<br>• សោធនឧត្តរជីវី | តំណាងបេឡាជាតិរបបសន្តិសុខសង្គម |
| ១០:១៥ -១០:៣០ | សម្រាកអាហារសម្រន់ | |
| ១០:៣០-១១:០០ | **<u>បទបង្ហាញស្តីពីៈ ប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈដោយផ្តោតសំខាន់លើសេវាកម្មចំនួនពីរដូចខាងក្រោមៈ</u>**<br>• សេវាពាក់ព័ន្ធវិស័យការងារ<br>• សេវាពាក់ព័ន្ធជនបរទេស | តំណាងក្រសួងការងារ |
| ១១:០០-១២:០០ | សំណួរនិងចម្លើយ | សម្របសម្រួលដោយៈ **លោក ជា វិបុល** អ្នកគ្រប់គ្រងផ្នែកអភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ |
| ១២:០០-១:៣០ | ពិសារអាហារថ្ងៃត្រង់រួមគ្នា | |
| ១:៣០-៣:០០ | **<u>បទបង្ហាញប្រភេទកិច្ចសន្យាការងារ អត្ថប្រយោជន៍នៃការបញ្ចប់កិច្ចសន្យាការងារ និងការអនុវត្តកាតព្វកិច្ចប្រាក់បំណាច់អតីតភាពការងារ</u>**<br>- ការអនុវត្តកិច្ចសន្យាការងារ<br>- ការព្យួរ និងរំលាយកិច្ចសន្យាការងារ<br>- ការអនុវត្តកាតព្វកិច្ចទូទាត់ប្រាក់បំណាច់អតីតភាពការងារ | តំណាងក្រសួងការងារ |
| ៣:០០-៣:១៥ | សម្រាកអាហារសម្រន់ | |

| | | |
|---|---|---|
| ៣:១៥-៤:០០ | បន្តប្រធានបទខាងលើ | តំណាងក្រសួងការងារ |
| ៤:០០-៤:៥០ | សំណួរនិងចម្លើយ | សម្របសម្រួលដោយៈ **លោក ជា វិបុល** អ្នកគ្រប់គ្រងផ្នែកអភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ |
| ៤:៥០-៥:០០ | បិទកម្មវិធី | **តំណាងក្រុមការងារគ្រប់គ្រងធនធានមនុស្ស** |

***<u>កំណត់សម្គាល់:</u>*** *អង្គការ គសក សូមរក្សាសិទ្ធិផ្លាស់ប្តូរ ឬ កែប្រែរបៀបវារៈនៃកម្មវិធីក្នុងករណីចាំបាច់។ អង្គការ គសក នឹងយករូបថតនៃវេទិការៀនសូត្រនេះសម្រាប់ការប្រើប្រាស់ផ្លូវការផ្សេងៗ។ សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់* *raingsey.roeung@ccc-cambodia.org*